## ៨-១-៦ បុណ្យចូលឆ្នាំខ្មែរ

*បុណ្យចូលឆ្នាំខ្មែរ មាន ៣ ថ្ងៃ ។ នៅប្រទេសខ្មែរយើង ទាំងរាជការ ទាំងប្រជារាស្ត្រ បានឈប់សំរាក អត់ធ្វើការងារទេ ទាំង៣ថ្ងៃនេះ។ គេស្លៀកពាក់ខោអាវល្អៗដើរទៅវត្តឬ ទៅលេងស្រុកកំណើត ជួបជុំបងប្អូន មីងមា ឪពុកម្តាយ ។*

*ថ្ងៃទី១ហៅថា“**មហាសង្ក្រាន្ត**”ជាថ្ងៃដែលទេវតាថ្មីត្រូវវេនមករក្សាពិភពលោកយើងនេះ។ នៅថ្ងៃទី១នេះអ្នកស្រុកយកចង្ហាន់បាយទឹកទៅប្រគេនព្រះសង្ឃនៅឯវត្ត ហើយនៅពេលរសៀលគេនាំគ្នាលេងល្បែងប្រជាប្រិយ ដូចជាបោះឈូង បោះអង្គុញ ជាដើម ។*

*ថ្ងៃទី២ ហៅថា “**វនបត**” ជាថ្ងៃដែលកូនចៅ យក អំណោយផ្សេងៗ មកជូនឪពុកម្តាយ ជីដូន ជីតា និងចាស់ព្រឹទ្ធាចារ្យ។ គេនាំគ្នាទៅវត្ត ដើម្បីពូនភ្នំខ្សាច់។*

*ថ្ងៃទី៣ ហៅថា“**ថ្ងៃឡើងស័ក**” ជាគម្រប់សង្ក្រាន្ត ៣ថ្ងៃ, ឆ្នាំថ្មីគឺចាប់ពី ថ្ងៃទី៣នេះទៅ។ ឡើងស័ក បានន័យថា គេតម្លើងស័ក មួយឯកតា ឧបមា បើស័កឆ្នាំចាស់ ៩ ស័កឆ្នាំថ្មី ៩+១ =១០ ហើយបន្ទាប់ពី ១០ ទៅ គេត្រឡប់មកស័ក ដំបូងវិញ គឺស័ក ១ ហៅថា ឯកស័ក ។ ដូច្នេះ ស័ក មានទាំងអស់១០ គឺ : ឯកស័ក ទោស: ត្រីស័ក ចត្វាស័ក បញ្ចស័ក ឆស័ក សប្តស័ក អដ្ឋស័ក នព្វស័ក សំរិទ្ធិស័ក។ ពិធីបុណ្យ ដែលគួរកត់សំគាល់នៅថ្ងៃឡើងស័ក គឺស្រង់ព្រះ ស្រង់ភិក្ខុសង្ឃ ងូតទឹកសំអាតខ្លួនប្រាណជូនឪពុកម្តាយ ជូនសំលៀកបំពាក់ថ្មីដល់គាត់ហើយសូមខមាទោសគាត់ ចំពោះទោសដែលកូនបានធ្វើដោយភ្លាំងភ្លាត់ និងដើម្បី សម្តែងនូវកតញ្ញូតាធម៌ ចំពោះឪពុកម្តាយ ផង ។*

*<u>សេចក្តីសង្កេត</u> :*

*ជាទម្លាប់ ក្នុងឱកាសសង្ក្រាន្ត ទាំង៣ថ្ងៃ ប្រជាជនប្រុស ស្រី បានរៀបចំទេវតាពលី ទទួលស្វាគមន៍ទេវតាឆ្នាំថ្មីនិង អុជប្រទីបផ្កាលា ថ្វាយព្រះរតនត្រ័យហើយខិតខំលះបង់*

ចិត្តអាក្រក់ ទម្លាប់អាក្រក់ (ដូចជាជក់បារី ផឹកសុរា) ដែលធ្លាប់មានក្នុងឆ្នាំចាស់នោះ ឲ្យជ្រះស្រឡះ ។

យើងត្រូវតាំងចិត្ត ប្រព្រឹត្តអំពើល្អក្នុងឆ្នាំថ្មីធ្វើបុណ្យដាក់ទាន តាមប្រពៃណីរក្សាសីល ឲ្យបានខ្ជាប់ខ្ជួន ។

ធ្វើយ៉ាងនេះ យើងនឹងមានសិរីសួស្តីសុភមង្គលវិបុលសុខគ្រប់ប្រការត្រជាក់ត្រជុំ អាយុយឺនយូរ តរៀងទៅ ហើយទេវតា ក៏លោក នឹងឲ្យពរសព្វសាធុការ ដល់យើងដែរ ។

វិលទៅរកទំព័រចាស់វិញ ដោយចុចលើព្រួញ " ← " ដែលនៅ កៀនកញ្ចក់ ខាងលើ និងខាងឆ្វេង។